# ប្រវត្តិ

# វត្ត ចំបក់បិនមាស



ស្រាវជ្រាវដោយ

ព្រះវិន័យធរ

អនុថេរោ ហួរ ហួន

ចៅអធិការទី ៦ វត្តចំបក់បិនមាស

ព.ស. ២៥៤៣ គ.ស. ១៩៩៩

LIBRARY BUDDHIST INSTITUTE

២១៤.
៣៧

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org



ព្រះវិន័យធរ អន្ទុថិតោ ហួរ ហួន
ចៅអធិការទី ៦ វត្តចំបក់បិទមាស

www.budinst.gov.kh www.elibraryofcambodia.org

២១៤.៣៧

# ប្រវត្តិ

# វត្ត ចំបក់បិទមាស



ស្រាវជ្រាវដោយ

ព្រះវិន័យធរ

អនុចំតោ ហួរ ហួន

ចៅអធិការទី ៦ វត្តចំបក់បិទមាស

៥៦៦៤/០០

ព.ស. ២៥៤៣ គ.ស. ១៩៩៩

www.budinst.gov.kh www.elibraryofcambodia.org

## វាចារបស់អ្នករៀបរៀង

## នមត្ថុ រតនត្តយស្ស

### សូមនមស្ការថ្វាយបង្គំដោយគោរពចំពោះព្រះរតនត្រ័យ

កាលដែលខ្ញុំករុណា អាត្មា ខិតខំចងក្រងនូវប្រវត្តិ **វត្តចំបក់បិទមាស** នេះឡើង ព្រោះគិតឃើញថា វត្តនេះមានប្រវត្តិជាយូរលង់ណាស់មកហើយ ប្រសិនបើ យើងមិនចារឹកទុកជាប្រវត្តិសាស្ត្រទេ ពុទ្ធបរិស័ទ និង អ្នកជំនាន់ក្រោយៗ ប្រាកដជាមិនដឹងថាវត្តនេះ ចាប់ផ្តើមកសាងឡើងពីឆ្នាំណា? ហើយទល់មកដល់សព្វថ្ងៃនេះ មានចៅអធិការប៉ុន្មានអង្គ? សមិទ្ធិផលក្នុងជំនាន់ចៅអធិការនិមួយៗ មានការចំរើនលូតលាស់ដល់កំរិតណា? ម្យ៉ាងចង់រក្សា ទុកនូវស្នាដៃរបស់បុព្វបុរស ដែលបានបង្កើតទឹកដីវត្តនេះ ទើបខ្ញុំ ករុណា-អាត្មា ខំព្យាយាមរៀបរៀងបន្តិចម្តងៗ រហូតមក ព្រោះខ្ញុំករុណា-អាត្មា បានសួរចាស់ទុំពីកំណើតរបស់វត្តចំបក់បិទមាសជាច្រើនជំនាន់ ដែលមាន **លោកយាយ ឈឹម ទូច** នៅភូមិកំពុងគោរ - **ព្រះតេជគុណ គង់អ៊ិត** ចៅអធិការ ទី៤ វត្តចំបក់បិទមាស និង ព្រះមេគណ ខេត្ត

www.budinst.gov.kh www.elibraryofcambodia.org

តាកែវព្រះនាម លុក ឃូ វុត្ថុនន្ទេបាទី ជាដើមជាភស្តុតាង ។

ខ្ញុំកូណា_អាត្មា មានបំណងធ្វើនូវប្រវត្តិនេះ ជាច្រើនជំនាន់ណាស់មកហើយ រហូតមកដល់ពេលនេះ ទើបមានឱកាសបោះពុម្ព ជាសៀវភៅនេះឡើង ដើម្បីទុកជាការយល់ដឹងដល់កូនចៅជំនាន់ក្រោយ ។

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរព្រះគុណ និងអំណរគុណ ចំពោះ :

- ឧបាសិកា គួយ ហាវ និងឧបាសិកា ខន ពៅ ដែលបានយកចិត្តទុកដាក់ជួយឧបត្ថម្ភជាទីបំផុត ក្នុងការបោះពុម្ពសៀវភៅនេះ ។

- ភិក្ខុ គង់ សារី និងអន្តិត ម៉ិល កំសត់ ដែលបានជួយសរសេរចម្លង ដើម្បីងាយស្រួលក្នុងការយកទៅបោះពុម្ព និងកែសម្រួលពាក្យពេចន៍ខ្លះៗ ព្រមទាំងជួយយកទៅបោះពុម្ពឱ្យចេញជារូបរាងសៀវភៅ នេះឡើង ។

- សប្បុរសជន ដែលមានសទ្ធាជ្រះថ្លាបានជួយឧបត្ថម្ភជាប្រាក់ដើម្បីបោះពុម្ពសៀវភៅនេះ ។

សូមអភ័យទោសនូវកំហុសឆ្គងគ្រប់បែបយ៉ាង ដែលមានការភ្លេចភ្លាំងខ្លះៗ មិនបានសរសេរក្នុងប្រវត្តិនេះ ប្រសិនបើ

www.budinst.gov.kh www.elibraryofcambodia.org

អស់លោកណាបានដឹងប្រវត្តិ វត្តចំបក់បិទមាស នេះជាងខ្ញុំករុណា អាត្មា សូមមេត្តាជួយផ្តល់ជាយោបល់ដោយអនុគ្រោះផង ។

វត្តចំបក់បិទមាស ថ្ងៃ ២ ១៥ ។ ១១

ត្រូវនឹងថ្ងៃទី ២២ ខែ វិច្ឆិកា ព.ស ២៥៤៣ / គ.ស ១៩៩៩

ព្រះវិន័យធរអនុចិតោ ឃួរ ឃួន

ចៅអធិការទី ៦ វត្តចំបក់បិទមាស

www.budinst.gov.kh www.elibraryofcambodia.org

# ដើមកំណើតវត្តចំបក់បិទមាស

កាលពីដើមខ្ញុំកូណា អាត្មាបានសួរលោកយាយម្នាក់ឈ្មោះ **ឈឹម ទូច** នៅភូមិកំពុងគោរ គាត់ដំណាលថា កាលគាត់នៅពីក្មេងតូចឮចាស់ៗ និយាយថា វត្តចំបក់បិទមាសនេះ កាលពីដើមឡើយនៅឯទួលតាសៅឯណោះទេ ប៉ុន្តែក្រោយមកវត្តនេះពុំសូវមានព្រះសង្ឃគង់នៅច្រើនណាស់ពីរឬក៏បី បួនអង្គប៉ុណ្ណោះ មិនចាំឆ្នាំមិនដឹងជាគ្រឹស្តសករាជប៉ុន្មាន កាលដែល ខ្ញុំកូណាអាត្មាសួរគាត់ គឺនៅគ.ស ១៩៦១ កាលណោះលោកយាយ **ឈឹម ទូច** អាយុ ៨០ ឆ្នាំ ។

លោកយាយ **ឈឹម ទូច** គាត់ថា បារាំងបានដុតវត្តទួលតាសៅទាំងថ្ងៃត្រង់ ដោយចោទលោកសង្ឃថា ធ្វើវិទ្ធង្សនាដេញបារាំងទៅស្រុក ហេតុនេះហើយបានជាពួកគេដុតវត្តនេះចោល ។ ពុទ្ធបរិស័ទចំណុះជើងវត្ត ព្រមទាំងរដ្ឋអំណាចមូលដ្ឋានទាំងអស់ក៏ប្រជុំគ្នាដើម្បីរើសរកកន្លែងធ្វើវត្តថ្មីទៀត រកទៅរកមកក៏ឃើញដីមួយកន្លែងគឺដីវត្តចំបក់បិទមាសសព្វថ្ងៃនេះ វត្តនេះកាលដើមឡើយមានតែទួលមួយដុំចំតួព្រះវិហារនេះឯង ក្រៅពីនោះសុទ្ធតែ

www.budinst.gov.kh www.elibraryofcambodia.org

ដីទំនាបទាំងរស់ ហើយសុទ្ធតែព្រៃរនាម មានដើមត្រស់ - រាំង - បបួយ - ស្គា - បបុស - ខ្ទុំ - ចារជាដើម ចំណែកនៅលើទួលនេះមានដើមចំបក់មួយដើមយ៉ាងធំ ក្នុងជំនាន់នោះប្រជាពលរដ្ឋ មានភ័យអាសន្នក៏មកបន់ស្រន់ដើមចំបក់នេះ ព្រោះគេមានជំនឿថាវត្ថុស័ក្តសិទ្ធិនៅថែរក្សាទីនេះ បើកាលណាគេបន់បានសំរេចដូចសេចក្តីប្រាថ្នារបស់គេ គេយកមាសសន្លឹកទៅបិទដើមចំបក់នោះ ដើម្បីលាបំណន់កុំអោយជាប់ពាក្យសំដីទៅថ្ងៃក្រោយ ។

ហេតុនេះ បើខ្ញុំអ្នកសរសេរគិតទៅមនុស្សក្នុងជំនាន់នោះមិនសូវមានការប្រមាទទេ ច្រើនប្រើពាក្យសច្ចៈណាស់ បើខ្លួននិយាយយ៉ាងម៉េចមុខតែធ្វើអញ្ចឹងហើយ ! បើអ្នកណារកបានវត្ថុអ្វីមកពីព្រៃក៏ចែកគ្នាហូបគ្មានលក់ ដូរយកលុយទេ រាប់អាន និងស្រលាញ់គ្នាណាស់ ដូចបងប្អូនបង្កើតរួមផ្ទៃ តែមួយគ្មានបេះភូតកុហកគ្នាទេ ។

ដល់ប្រជុំគ្នាប្តូរយោបល់គ្នាទៅ ក៏កំណត់យកដីទីទួលនេះធ្វើជាវត្ត នៅក្នុងឆ្នាំ ១៧៩៧ ហើយបានស្រុះស្រួលបបួលគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ទៅនិមន្ត ព្រះតេជគុណ ឪទុក ភែ ពីវត្តឆ្នាត់ ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ មកគង់នៅវត្តនេះ ហើយក៏ហៅឈ្មោះវត្តនេះថា វត្តទាំងរនាម រហូតមក ពីព្រោះមានព្រៃ រនាម គឺដើមត្រស់ - បបួយ - រាំង - ស្លា - ចារ - រទាំងជាដើម លុះដល់ ពេលមក ខាង ក្រោយ ក៏ផ្លាស់ ឈ្មោះវត្តតាមផ្លូវការ សមស្របតាម លំនាំដើម គឺមានដើម ចំបក់ជាភស្តុតាង ក៏ដាក់ឈ្មោះថា **វត្តចំបក់បិទមាស** ខណ្ឌក្រុង ខណ្ឌបាទី ខេត្តតាកែវ ។ លុះដល់ មកខាងក្រោយមកទៀត ក៏ផ្លាស់ខណ្ឌក្រុងមក ឃុំពត់សវិញ រហូត មកដល់សព្វថ្ងៃនេះ ។ សូមជំរាបអ្នកជំនាន់ ក្រោយអោយ ដឹង ដែលខ្ញុំបានស្រាវជ្រាវសួរចាស់ទុំ ជាពិសេសព្រះតេជគុណ **គង់ ឪត** ជាចៅអធិការទី៤ វត្តចំបក់បិទមាស និងព្រះតេជគុណ **លុក យូ** វត្តទន្លេបាទី មេគណខេត្តតាកែវ ។

ចៅអធិការ វត្តចំបក់បិទមាសទី១ ព្រះនាម ឪទុក ភែ ក៏ចាប់កសាងសំណង់ផ្សេងៗ មានកុដិ សាលាធម្មសភា ព្រះវិហារ និងចាក់ដីក្រហែង ក្រហួងអោយទីវត្តរាបស្មើ ជាមួយពុទ្ធ បរិស័ទ និង ព្រះសង្ឃព្រមទាំងរដ្ឋអំណាចផង ដោយមានការសាមគ្គី

www.budinst.gov.kh www.elibraryofcambodia.org

ស្ថិតរមួតរួមកម្លាំងក្នុងផ្នែកកសាងព្រះពុទ្ធសាសនា និងកសាងសង្គមគ្រប់ផ្នែក ពុទ្ធបរិស័ទទាំងឡាយចំណុះជើងវត្ត ក៏មានសេចក្តីជ្រះថ្លា ចំពោះព្រះតេជគុណណាស់ ក្នុងជំនាន់នោះព្រះតេជគុណ ទ្រឹក កែ គង់នៅវត្តចំបក់បិទមាស ហៅ (វត្តទាំងរនាម) ពេលយប់នៅក្នុងវត្ត គេឮតែសូរស័ព្ទធម៌អារ្យដែលភិក្ខុ-សាមណេរ ក្មេងរៀនសូត្រ ទ្រហ៊ឹងអ៊ឹងកង ។ ចំណែកនៅខាងក្រៅវត្តវិញ ឮសូរតែសត្វ មាន់ព្រៃរងាវ - ចចកលូ - ទីទុយយំ - មៀមមំ - អាអូត - ខ្លាព្រី - សំពោច ត្រយ៉ង - កុកសាប់ - កុកស - កន្ត្រុំ - ផ្លុំ - មាន់ទឹក - ទោម - កុកសក ជាដើមនៅបឹងត្រស់ខាងជើងវត្តនេះ សុទ្ធតែព្រៃរនាមគ្មាននរណាធ្វើស្រែដូចសព្វថ្ងៃនេះទេ ឮតែសត្វយំឆ្លើយឆ្លងគ្នា គួរអោយរីករាយជ្រះថ្លាពន់ពេក ។

ហេតុនេះបានជាពុទ្ធបរិស័ទ មកដេកកំដរយប់ៗ ព្រះតេជ-គុណ ទ្រឹក កែ គង់នៅយូរទៅក៏មានប្អូនរបស់លោកម្នាក់ឈ្មោះតា នង យាយ ទៀ មកតាមលោកនៅខាងលិចវត្តនេះបែកកូនពូនជាចៅរហូត ដល់សព្វថ្ងៃនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

និយាយមកដល់ត្រង់នេះ យើងនិយាយពី ព្រះតេជគុណ អ៊ុក កែ ដែលព្រះអង្គគង់នៅជាមួយភិក្ខុ-សាមណេរ ក្នុងវត្តទាំងប៉ុន្មាន ក៏ចេះតែសុខសប្បាយរៀងរហូត បើតាមចាស់ទុំនិយាយតៗ គ្នាមកថា គឺលោកតា អ៊ុក ភូមិខ្វាន់មាស លោកតា ភឹម ប៊ិន ភូមិចំបក់គាត់ដំណាលប្រាប់ថា វត្តក្នុងជំនាន់នោះ ព្រះតេជគុណ អ៊ុក កែ ដឹកនាំភិក្ខុ-សាមណេរ ពុទ្ធបរិស័ទ ជំនាន់នោះ មានការជឿនលឿនខ្លាំងក្លាជាទីបំផុត ផ្នែកខាងសង្គមជាតិ និង ពុទ្ធសាសនា ពីព្រោះព្រះអង្គឈ្លាសវៃក្នុងការដឹកនាំ ហើយព្រះអង្គមានទេពកោសល្យខ្ពស់ មានប្រជាប្រិយភាពចំពោះ ភិក្ខុ-សាមណេរ ពុទ្ធបរិស័ទ ទូទៅ ។

លុះដល់ព្រះអង្គចាស់ជរា ក៏ព្រះអង្គបានធ្វើសមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន អប់រំបន្ទុំចិត្តរបស់ព្រះអង្គ សម័យថ្ងៃមួយព្រះអង្គបាន និមន្តទៅធ្វើធម៌ នៅឯទួលខ្មោចខាងកើតវត្ត ស្រាប់តែជួបប្រទះនឹងក្របីកូន នៅខណៈនោះ ក្របីក៏ដេញវ៉ៃព្រះតេជគុណ អ៊ុក កែ ធ្វើអោយព្រះអង្គរត់មិនរួចក៏សុគតក្នុងទីនោះទៅ បើតាមចាស់ទុំដំណាលថា ព្រះអង្គសុគតក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ពេលយប់ឬក៏ជិតភ្លឺ ពីព្រោះភ្លឺឡើង ភិក្ខុ-សាមណេរ រកលោក មិនឃើញនៅក្នុងវត្ត ។ ហេតុនេះក៏ចាត់គ្នារកក្រៅវត្ត ស្រាប់តែដើរទៅឃើញព្រះអង្គសុគតដោយក្របីវ៉ៃ រយះរយាយពេញទាំងខ្លួនគួរអោយអាណោចអាធម្ម ពន់ពេកណាស់ ។

ក្នុងសម័យនោះ គេនិយមទូងស្គរ កាលណាមានហេតុភេទអ្វីមិនស្រួលនៅក្នុងវត្ត ។ ពេលនោះក៏រកឃើញលោកដូច្នោះភិក្ខុ-សាមណេរ ចាត់គ្នាទូងស្គរ ម៉្លោះហើយពុទ្ធបរិស័ទសិស្សានុសិស្ស រដ្ឋអំណាច ភូមិ ឃុំ ឮសំឡេងស្គរដូច្នោះក៏មកគ្រប់ទិសទី ឆោឡោគ្រប់គ្នា តើវត្តយើងមានហេតុអ្វី ?

លុះពុទ្ធបរិស័ទ រដ្ឋអំណាច មកជួបជុំគ្នាក្នុងវត្តហើយ ភិក្ខុ-សាមណេរ បានរាយការណ៍ប្រាប់រឿងហេតុនោះសព្វគ្រប់ ថាព្រះតេជគុណរបស់យើងព្រះនាម ឡុក ភែ ត្រូវក្របីវ៉ៃសុគតហើយ នៅខាងមុខវត្តឯណោះ ពុទ្ធបរិស័ទ សិស្សានុសិស្សទាំងប៉ុន្មានគ្រាន់តែឮថា ព្រះតេជគុណសុគតដោយក្របីវ៉ៃដូច្នោះក៏មានសេចក្តីតក់ស្លុត សោកស្តាយ យំខ្សឹកខ្សួលយ៉ាងខ្លាំង ក៏បបួលគ្នាទៅយកព្រះសពពីព្រៃមុខវត្តនោះ ធ្វើមឈ្នូសដាក់ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

សព ដំកល់លើសាលាធម្មសភា បើតាមចាស់ទុំដំណាលត១គ្នា មកថា ដំកល់ព្រះសពលើសាលាធម្មសភាចំនួនមួយឆ្នាំ ពីព្រោះក្នុងជំនាន់នោះ គេនិយមដំកល់ទុកធ្វើជាសក្ការៈអោយបានយូរខែឆ្នាំណាស់ ។ ក្រោយមកក៏បានជំនុំគ្នារកថ្ងៃ ខែធ្វើបុណ្យបូជាព្រះសព ហៅថា (បុណ្យឡើងសាលា) ៧ យប់ ៧ ថ្ងៃទៀត លុះបុណ្យព្រះសពព្រះតេជគុណ **អ៊ុក កែ** រួចហើយ ពុទ្ធបរិស័ទ រដ្ឋអំណាច ភិក្ខុ-សាមណេរ **វត្តចំបក់បិទមាស** ហៅថា (វត្តទាំងរនាម) ក៏គិតជំនុំគ្នារកចៅអធិការគ្រប់គ្រងវត្តតទៅទៀត ។

ក៏សម្រេចប្រគេនឋានៈភិក្ខុ **អ៊ុក សោម** ឡើងជាចៅអធិការពេញលក្ខណៈច្បាប់ នេះជាចៅអធិការទី ២ វត្តចំបក់បិទមាស ។ ព្រះតេជគុណ **អ៊ុក សោម** កំណើតរបស់លោកនៅដើមឫស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល លោកចេះវិជ្ជាផ្នែកខាងគុនដំបង និងប្រដាល់ចំបាប់យ៉ាងស្ទាត់ជំនាញ ។ ហេតុនេះព្រះតេជគុណ **អ៊ុក សោម** ក៏ចេះតែនាំភិក្ខុ-សាមណេរ ពុទ្ធបរិស័ទ ចំណុះជើងវត្តចំបក់បិទមាស ចាក់ដីក្រហេងក្រហូងមួយឆ្នាំបន្តិច១ ឱ្យទីដីវត្តរាបស្មើ ហើយឱ្យដីវត្តធំទូលាយ ចំណែក

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គមានប្រជាប្រិយភាព ទៅលើពុទ្ធបរិស័ទ ភិក្ខុ-សោមណេរ សិស្សានុសិស្សណាស់ ក្នុងជំនាន់នោះពុទ្ធសាសនិកខ្មែរ កាន់ពុទ្ធសាសនាមួយរយភាគរយ ហើយក្នុងរបបអាណានិគមបារាំងសេសត្រួតត្រាទឹកដីប្រទេសកម្ពុជាយើង ហេតុនេះអក្សរសាស្ត្រខ្មែរបានរត់ទៅជ្រកក្រោមម្លប់ព្រះពុទ្ធសាសនា គឺវត្តអារាមនេះឯង ភិក្ខុសង្ឃក្នុងជំនាន់នោះចារស្លឹកត្នោត ស្លឹករិតឱ្យកូនខ្មែររៀនសូត្រ ឱ្យចេះដឹងអក្សរខ្មែរ នេះគឺពិតណាស់មិនអាចប្រកែកបានពីព្រោះអ្នកសរសេរប្រវត្តិរបស់វត្ត បានកើតទាន់ក្នុងជំនាន់បារាំងសេស ដែលគេបានត្រួតត្រាទឹកដីរង្គរដ៏បវរ របស់យើងមួយសតវត្សរ៍ ។

និយាយពីព្រះតេជគុណ **អ៊ុក សោម** បានកសាងព្រះវិហារ ដោយមានមន្ត្រីម្នាក់ឈ្មោះ **គោះម៉ៅខារ** មន្ត្រីកុត្តរាជធ្វើការនៅវាំងជួយឧបត្ថម្ភ ក្នុងការកសាងព្រះវិហាររួមជាមួយពុទ្ធបរិស័ទគ្រប់ទិសទី ដែលមានសទ្ធាជ្រះថ្លាចំពោះការកសាងព្រះវិហារ មិនយូរប៉ុន្មានក៏ហើយជាស្ថាពរ មន្ត្រីកុត្តរាជនេះដើមកំណើតនៅភូមិតាំងឫស្សី កាលណាសាងសង់ព្រះវិហាររួចហើយ

www.budinst.gov.kh www.elibraryofcambodia.org

គាត់យកកណ្ដឹងមកចងតាមជហ្វាដងក្ដារ និង នាគព្រះវិហារ ពេលខ្យល់បក់បោកមកគេឮសូរតែកណ្ដឹង ហាក់ដូចជាបទភ្លេងរងំ គួរឱ្យជ្រះថ្លាពន់ពេកណាស់ ក្នុងជំនាន់ចៅអធិការ អ៊ុក សោម រួចកសាងសាលាធម្មសភា កុដិថែវ តូច - ធំ ធ្វើកំផែងវត្តចាក់ព័ទ្ធជុំវិញទៀត ហើយធ្វើក្លោងទ្វារទាំងបួនទិស គឺ ទិសខាងកើត - ខាងលិច - ខាងជើង - ខាងត្បូង សុទ្ធតែក្បាច់ រង្គរវត្ត ។

ខ្ញុំអ្នកសរសេរឃើញរឿងនេះពិតប្រាកដ ព្រោះខ្ញុំទាន់ក្លោងទ្វារពីរគឺ : ក្លោងទ្វារខាងកើតមួយ និងខាងលិចមួយ ជាភស្តុតាងស្រាប់ កាលខ្ញុំនៅវត្តពីក្មេងអាយុ ១០ ឆ្នាំ វត្តចំបក់បិទមាសជំនាន់នោះ រុងរឿងណាស់ជាមហាវត្តមួយ ក្នុងបណ្ដាវត្តនៅស្រុកបាទី ខេត្តតាកែវ ។ ព្រះពេជគុណចៅអធិការ អ៊ុក សោម មានឋានៈជាព្រះបាឡាត់គណ ខេត្តតាកែវ ក្នុងជំនាន់ព្រះបាឡាត់គណ អ៊ុក សោម គ្រប់គ្រងវត្តចំបក់បិទមាស ភូមិរបស់អ្នកស្រុកគ្មាននៅជិតវត្តទេ មានតែភូមិមួយទេ គឺភូមិដងទង់ ភូមិនេះមានតែផ្ទះពីរឬបីនៅខាងត្បូងវត្ត ឥឡូវនេះគ្មានផ្ទះទេ នៅតែទួលទទេ ។ និយាយពីព្រះបាឡាត់ អ៊ុក សោម លោកកាន់តែមានវ័យចាស់

www.budinst.gov.kh www.elibraryofcambodia.org

ជរា លោកក៏សុគតក្នុងព្រះជន្ម ៨០ ឆ្នាំគត់ នេះបើតាមខ្ញុំសួរព្រះចៅអធិការទី ៤ ព្រះនាម គង់ អិត វត្តចំបក់បិទមាស លោកដំណាលថា គេដំកល់សពរបស់លោកមួយឆ្នាំគត់ ទំរាំធ្វើបុណ្យឡើងសាលារំលាយសព ឆ្នាំនោះគឺមានការរាំងភ្លៀងមួយឆ្នាំ ពុទ្ធបរិស័ទចំណុះជើងវត្តគ្មានបានធ្វើស្រែទេ នេះបើតាមព្រះមេគណខេត្តតាកែវ វត្តទន្លេបាទី ព្រះនាម លុក យូ ដំណាលប្រាប់ខ្ញុំ ។

ប៉ុន្តែទោះជាមិនបានធ្វើស្រែយ៉ាងណាក៏ដោយ ក៏នៅតែធ្វើបុណ្យរំលាយសព របស់លោកយ៉ាងអធិកអធមក្រៃលែង គឺ ធ្វើ ៧ យប់ ៧ ថ្ងៃទើបហើយ ។ សូមបញ្ជាក់ថា ព្រះតេជគុណអង្គនេះមានបុណ្យណាស់ សុគតហើយនៅក្នុងក្តារមឈូស ហាក់ដូចជាព្រះអង្គគង់ព្រះជន្មាយុនៅឡើយ ពីព្រោះសិស្សានុសិស្ស ពុទ្ធបរិស័ទនៅតែគោរពបូជា នៅពេលល្ងាចកូនសិស្ស ពុទ្ធបរិស័ទមកសូធ្យធម៌ប្រគេនរៀងរាល់ថ្ងៃយប់ រហូតដល់ថ្ងៃ - ខែ - ឆ្នាំធ្វើបុណ្យរំលាយសព នៅឆ្នាំជូតគិតមកដល់ឆ្នាំ ១៩៩៧ ត្រូវជា ៩៨ ឆ្នាំហើយ អដ្ឋិធាតុ (ឆ្អឹង) របស់លោកទិព្វមាសទៀត នេះគឺខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org

បានរើសធាតុរបស់លោកដែលចោរវាលួចយកគោដ្ឋ ហើយវាចាក់ចោលនៅក្នុងចេតិយ៍ធំ ដែលកូនសិស្ស ពុទ្ធបរិស័ទ កសាងប្រគេនចំពោះលោក ដែលឋិតនៅជ្រុងអាគ្នេយ៍ នៃព្រះវិហារ ប៉ុន្តែនៅក្នុងជំនាន់ប៉ុល ពត ពួកគេរំលាយចោលអស់គ្មានសេសសល់ទេ ។

លុះធ្វើបុណ្យរួចហើយ ភិក្ខុ-សាមណេរ ពុទ្ធបរិស័ទចំណុះជើងវត្តចំបក់បិទមាសទាំងមូលបានគិតគ្នា ជ្រើសរើសចៅអធិការថ្មីទៀត ដើម្បីគ្រប់គ្រងភិក្ខុ-សាមណេរនៅក្នុងវត្ត ក៏បបួលគ្នាធ្វើច្បាប់បញ្ជូនទៅសាលាអនុគណស្រុកបាទី ដើម្បីជ្រើសរើសចៅអធិការថ្មី ។ មេគណខេត្តតាកែវ ក៏ចាត់ព្រះបាឡាត់ **ម៉ិត** នៅវត្តទន្លេបាទី ឱ្យភិក្ខុ-សាមណេរជ្រើសរើសតាមច្បាប់ ក៏បានលោកគ្រូសូត្យ **ព្រាប ទូច ព្រហ្មកេសរោ** ជាប់ឆ្នោតឡើងជាចៅអធិការ វត្តចំបក់បិទមាស ពេញលក្ខណៈច្បាប់ក្នុងព្រះជន្មាយុ ៤៤ ឆ្នាំ ព្រះតេជគុណ **ព្រាប ទូច** បានឡើងជាចៅអធិការហើយក៏ចាប់មើលការខុសត្រូវ ភិក្ខុ-សាមណេរក្នុងវត្ត ហើយព្រះអង្គមានប្រជាប្រិយភាពលើភិក្ខុ-សាមណេរ ពុទ្ធបរិស័ទចំណុះ

www.budinst.gov.kh www.elibraryofcambodia.org

ជើងវត្ត ព្រះអង្គមិនចេះនិយាយច្រើនទេ តែថាគំនិតមាននៅក្នុងខ្លួនព្រះអង្គ ជានិច្ចជាកាលព្រះអង្គមានវិជ្ជាសាស្ត្រខាងលេខខ្មែរ ព្រះអង្គជាជាងសំណង់គ្រប់បែបយ៉ាង គឺព្រះអង្គចេះធ្វើពិតប្រាកដណាស់ ធ្វើកុដិ - សាលាធម្មសភា - ព្រះវិហារ ។ ខ្ញុំករុណាអាត្មាជាអ្នកសរសេរនេះ ជាកូនសិស្សរបស់លោក ហើយព្រះតេជគុណ ព្រាប ទូច ត្រូវជាឧបជ្ឈាយ៍របស់ខ្ញុំ កាលខ្ញុំបួសជាសាមណេរអាយុ ១៣ ឆ្នាំ ។

កាលជំនាន់ចៅអធិការ ព្រាប ទូច មានការរីកចម្រើនយ៉ាងក្រៃលែង ផ្នែកកសាងសំណង់មានកើតព្រោងព្រាតដូចជាផ្សិត គឺ : កុដិប្រាំបីខ្នង, សាលាធម្មសភា ១, ព្រះវិហារ ១, រោងវែង ១, សាលាបង្សុកូល ១, មេរុ ១, ចេតិយ៍ប្រាំ, បង្គន់បួនបន្ទប់ ១, សាលាបឋមសិក្សាបួនបន្ទប់ ១ ។ ផ្នែកខាងអក្សរសាស្ត្រមានការរីកចំរើនខ្លាំងណាស់ដែរ ព្រះអង្គចាត់ចែងឱ្យមានគ្រូសូធ្យរហូតដល់ប្រាំបីអង្គ លោកគ្រូសូធ្យទាំងនេះមានតួនាទីដូចតទៅ :

១- លោកគ្រូសូធ្យស្តាំ **មាស ឈឹម** បង្រៀនផ្នែកខាង

www.budinst.gov.kh www.elibraryofcambodia.org

អក្សរសាស្ត្រ និងសាត្រាទេសន៍គ្រប់បែប ។

២. លោកគ្រូសូធ្យឡេង គង់ ឪត ខាងលេខសាំងពូ គឺលេខចិន ។

៣. លោកគ្រូសូធ្យ ឪក ម៉ែន បង្ហាត់កូនសិស្សទេសន៍មហាជាតិបទបែបផ្សេងៗ ។

៤. លោកគ្រូសូធ្យ គាំ ឆ្នាក់ ខាងកសាងសំណង់គ្រប់មុខ មានសាលារៀនជាដើម ។

៥. លោកគ្រូសូធ្យ ស្រី នុត បង្ហាត់ក្មេងសាលាអនុវត្តក្នុងជំនាន់បារាំងសេសត្រួតត្រាទឹកដីខ្មែរ ព្រមទាំងវិបស្សនាធុរៈកម្មដ្ឋានផង ។

៦. លោកគ្រូសូធ្យ ឈ៉ត បង្រៀនអក្សរក្មេងនៅកុដិ ។

៧. លោកគ្រូសូធ្យ ខៀវ យ៉ា កសាងយ៉ព្រះវិហារ - កុដិ- ប៉ូសផុលកុដិ - សាលាធម្មសភាជាដើម ។

៨. លោកគ្រូសូធ្យ មាស កែប ខាងបារស្លឹករិតឱ្យភិក្ខុ-សាមណេរ - ក្មេងរៀនសូត្រតាមសម័យនោះ (សម័យបារាំងសេស) ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងជំនាន់ចៅអធិការ ព្រាប ទូច មានកូន សិស្សរបស់លោកពីររង្គគឺ ភិក្ខុ លុក យូ ១ , ភិក្ខុ គាំ ១ ក្នុងពេលមានបុណ្យ តូច-ធំ ដូចជាបុណ្យឡើងសាលា ពុទ្ធបរិស័ទនិយមរាប់អានទេសន៍មហាជាតិណាស់ គឺ: រឿងវេស្សន្តរជាតក ល្បីល្បាញរន្ទឺសព្ទទិសទី កូនសិស្សទាំងពីររង្គនេះ ។

លុះពេលខាងក្រោយមកព្រះតេជគុណបាឡាត់ ម៉ិត វត្តទន្លេបាទី បានសុំភិក្ខុ លុក យូ ពីព្រះតេជគុណ ព្រាប ទូច យកទៅនៅវត្តទន្លេបាទី តាំងពីលោកអាយុ ២០ ឆ្នាំ ។ ចំណែកភិក្ខុ គាំ គេនិមន្តទៅធ្វើចៅអធិការ វត្តព្រៃកលឹវ ទន្លេធំ សូមបញ្ជាក់ថា ភិក្ខុពីររង្គខាងលើនេះ ទៅរហូតដល់សុគតឥតមកនៅវត្តដើម (វត្តចំបក់បិទមាស) វិញទេ ។

មានកូនសិស្សមួយរង្គទៀត ក៏ល្បីល្បាញណាស់ដែរ គឺព្រះអាចារ្យ ស្រី នុត បង្ហាត់បង្ហាញខាងផ្លូវវិប្បស្សនាធុរៈ មានភិក្ខុ-សាមណេរ - ពុទ្ធបរិស័ទ រៀនសូត្ររាប់ពាន់នាក់ ។ ខ្ញុំអ្នកសរសេរសូមបញ្ជាក់ថា ចៅអធិការ ព្រាប ទូច ពេលដែលលោកចាស់ជរាទៅ លោកសព្វព្រះទ័យខាងសម្អាតវត្តអារាម

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ ពេលព្រឹកបោសសំរាម ពេលល្ងាចបោសសំរាម ឯសម្ភារៈរបស់លោកគឺ : បង្គី ១ - ចបចក់ ១ - អំបោស ១ ព្រះតេជគុណពេញព្រះទ័យចម្រើនរវដ្ដៈ ១០៨ ចប់ ទើបថ្វាយបង្គំព្រឹកល្ងាចជាអចិន្ត្រៃយ៍ នេះគឺជាកិច្ចវត្តរបស់លោក ។

នៅទីបញ្ចប់ជីវិតរបស់លោក ព្រះអង្គមានជន្មាយុ ៨៨ ឆ្នាំ ពេលដែលលោកប្រឈួនមិនបានយូរទេ ព្រោះលោកកើតជម្ងឺបុកតែមួយយប់មួយថ្ងៃប៉ុណ្ណោះក៏សុគតតែម្ដង ក្នុងចំណោមភិក្ខុ-សាមណេរ - ពុទ្ធបរិស័ទ - សិស្សានុសិស្ស នៅវេលាម៉ោង ៩ ព្រឹក ថ្ងៃ-ខែ-ឆ្នាំ មិនបានចាំច្បាស់ ។ ចៅអធិការ ទី ៣ **ព្រាប ឡូច** កំណើតរបស់លោកនៅភូមិ តាំងឫស្សី ។

ព្រះតេជគុណ **ព្រាប ឡូច** សុគតទៅចាប់ជ្រើសរើសចៅអធិការថ្មីទៀតដើម្បីគ្រប់គ្រងវត្ត ភិក្ខុ-សាមណេរ ធ្វើច្បាប់ថ្មីមួយបញ្ជូនតាមផ្លូវការទៅសាលាអនុគណ នៅវត្តទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ភិក្ខុ-សាមណេរសម្រេចបោះឆ្នោត បានជាប់ទៅលើព្រះតេជគុណ **គង់ ឡឹត** ជាចៅអធិការថ្មីពេញលក្ខណៈច្បាប់ ។ ព្រះតេជគុណអង្គនេះ បានឡើងជា

www.budinst.gov.kh www.elibraryofcambodia.org

ចៅអធិការហើយ ក៏ចាត់ការរៀបចំវត្តចំបក់បិទមាស ឱ្យមានធម៌វិន័យស្ថិតនៅក្នុងវត្ត សមជាអ្នកបួសកាន់ព្រះពុទ្ធសាសនា ។ ផ្នែកកសាងសំណង់តូចធំ ចាប់ផ្តើមកសាងធាតុចេតិយ៍ ហៅ (ប្រាង្គ) នៅជ្រុងឥសាន្តនៃព្រះវិហារ ដើម្បីបញ្ចុះអដ្ឋិធាតុគ្រូរបស់លោក គឺព្រះតេជគុណ ព្រាប ទូច ព្រហ្មកេសរោ ព្រមទាំងព្រះសពដទៃទៀតគឺ : អ៊ុក ប៉ែន ១ , គាំ ប្រាក់ ១ , ខៀវ យ៉ា ១ , លោកតា ឆាត ១ , ស៊ូ ឡាច ១ , ចៅអធិការ គង់ អ៊ុត ១ សុទ្ធតែកោដ្ឋប្រាក់ទាំងរបស់ ប៉ុន្តែពួកខ្មែរក្រហមគេកំទេចចោលអស់រលីង ។ បាននាំពុទ្ធបរិស័ទទិញម៉ាស៊ីនភ្លើងមួយគ្រឿងសម្រាប់វត្ត និង កសាងវត្ថុដទៃទៀតជាច្រើន ជាពិសេសនៅឆ្នាំ ១៩៥៨ មានភិក្ខុ ៤ រង្គគឺ : ភិក្ខុ ព្រាប កែវ ១ , ភិក្ខុ អ៊ី សឿង ១. , ភិក្ខុ ហួរ ហួន ១ , ភិក្ខុ ព្រុំ អែម ១ ឡើងសុំព្រះតេជគុណ ចៅអធិការ គង់ អ៊ិត បើកសាលាពុទ្ធិកបឋមសិក្សានៅវត្តចំបក់បិទមាស បើកជាបីថ្នាក់ ថ្នាក់ទី១ ភិក្ខុ ហួរ ហួន បង្រៀន , ថ្នាក់ទី២ ភិក្ខុ ព្រាប កែវ , ថ្នាក់ទី៣ ភិក្ខុ អ៊ី សឿង រួមសមណសិស្ស ៥០ អង្គ ។

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនេះសូមជំរាបថា វត្តចំបក់បិទមាស អ្នកបើកសាលាបាលី គឺភិក្ខុ ៤ អង្គ ដូចជំរាបខាងលើមានសាលាបាលីផ្នែកខាងបរិយត្តិផង , វិបស្សនាធុរៈផង មានសាលារៀនបឋមសិក្សាក្មេងផង ។ ចៅអធិការ **គង់ អ៊ិត** ចាស់ជរា គឺខ្ញុំអ្នកសរសេរនេះត្រូវជាកូនសិស្សព្រះតេជគុណ **គង់ អ៊ិត** បានថែរក្សាព្រះអង្គផ្ទាល់ ពីព្រោះព្រះអង្គត្រូវជាឧបជ្ឈាយ៍បំបួសភិក្ខុភាពនាម **បង្វៀវតោ** ដល់ខ្ញុំ លោកគ្រូសូធ្យស្តាំនាម **ឆេព ជា** គង់នៅវត្តបុទុមសុរិយា , លោកគ្រូសូធ្យឆ្វេងនាម **ខៀវ យ៉ា** គង់នៅវត្តចំបក់បិទមាស ។ ព្រះអង្គចៅអធិការ **គង់ អ៊ិត** បានព្រះជន្ម ៨០ គត់ ព្រះអង្គជរាខ្លាំងណាស់ សិស្សានុសិស្ស ពុទ្ធបរិស័ទ រកពេទ្យមកព្យាបាលព្រះរោគរបស់ព្រះអង្គ ក៏នៅតែមិនជា ព្រះអង្គបានសុគតនៅថ្ងៃ ១រោច ខែ .អស្សុជ ចំថ្ងៃបុណ្យកឋិនតែម្តង ដែលមានឧបាសក **ម៉ម ម៉ារ៉ត** កំណើតនៅភូមិកោះ ឃុំបឹងខ្យាងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងពុទ្ធបរិស័ទបាននាំ កឋិនចូលមកវត្តចំបក់បិទមាស សូមបញ្ជាក់ថា កឋិនឆ្នាំហ្នឹង ព្រះអង្គ **គង់ អ៊ិត** គ្រងកឋិន គ្រាន់តែកឋិនទាន់ដង្ហែរចូលព្រះវិហារ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គក៏រៀបចំចូលព្រះវិហារដែរ ពេលនោះស្រាប់តែសុគតភ្លាម នៅក្នុងកុដិដោយមាន ភិក្ខុ **ហួរ ហួន** និងក្មេងម្នាក់ទៀតឈ្មោះ **ស៊ឹម សែម** នៅជាមួយព្រះអង្គ ។ កឋិនឆ្នាំហ្នឹងបានវេរប្រគេន លោកគ្រូសូធ្យ **ខៀវ យា** គ្រងកឋិនវិញ បានប្រាក់សង្កត់ត្រៃ ១០០០០ រៀល យកមកចាត់ចែងធ្វើបុណ្យព្រះសព **គង់ អ៊ិត** អស់ទៅ ។ នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ឆ្នាំ ១៩៥៨ ចៅអធិការ **គង់ អ៊ិត** សុគត ហើយអ្នកដឹកនាំធ្វើបុណ្យសពរបស់លោកគឺ ព្រះអាចារ្យ **ស្រី នុត** បានធ្វើបុណ្យប្រគេន ៧ យប់ ៧ ថ្ងៃ ទើបហើយស្រេច (នេះចៅអធិការទី ៤) ។

អស់ពីព្រះតេជគុណ **គង់ អ៊ិត** ហើយចៅអធិការ ក៏ធ្លាក់លើ ភិក្ខុ **ហួរ ហួន** ស្តីទីដល់ គ.ស ១៩៥៩ - ១៩៦០ ចៅអធិការស្តីទី **ហួរ ហួន** ទៅរកអាចារ្យមកបង្រៀនសាលាបាលី គឺអាចារ្យ **ផាន់ ផេង** និមន្តមកពីវត្តកោះ ភ្នំពេញ កំណើតនៅស្រុកកញ្ជ្រាជ ខេត្តព្រៃវែង ។ ដល់ គ.ស ១៩៦០ វត្តចំបក់បិទមាសក្នុងពេលនោះ ធ្លាក់ជុនជាបមួយកំរិតធំ ពីព្រោះអស់ពីលោកចាស់ទុំទៅ នៅតែលោកក្មេងៗ ម៉្លោះហើយ ពុទ្ធបរិស័ទចំណុះ

www.budinst.gov.kh www.elibraryofcambodia.org

ជើងវត្តគេពុំសូវជ្រះថ្លា ក្នុងសម័យនោះរៀបធម៌វិន័យ ដើម្បីឱ្យព្រះសង្ឃរៀនសូត្រ ដូច្នេះពុទ្ធបរិស័ទមិន ទាន់យល់ក៏ប្រកាន់ធម៌ថ្មី ធម៌ចាស់ ។ និយាយពីលោកអាចារ្យ អ៊ុំ សឿន វិញនៅគ.ស ១៩៥៩ ក៏លាចាកសិក្ខាបទទៅ ឯអាចារ្យ ព្រាប កែវក៏ទៅនៅវត្តទន្លេបាទី ។ គ.ស ១៩៦១ ចៅអធិការស្តីទី ហួរ ហួនប្រធានវត្ត គីម ប៊ីន ភិក្ខុ ព្រាំ ឯម បានជំនុំគ្នាពីរឿងវត្តវ៉ា ដើម្បីឱ្យរីកចំរើនឡើងវិញ ពេលនោះស្របយោបល់គ្នាថា ទៅនិមន្តព្រះអាចារ្យ ស្រី នុត គង់នៅខេត្តបាត់ដំបង ភូមិអណ្តើកហែបខាងជើងភ្នំវាយចាប ផ្លូវទៅប៉ៃលិន ពីទីក្រុងខេត្តបាត់ដំបងស្រុកបាត់ដំបងចម្ងាយផ្លូវ ៣០ គ.ម ចុះពីផ្សារស្ពៅ ទៅទិសខាងកើតចំនួន ៣ គ.ម ដល់កន្លែងព្រះអាចារ្យ ស្រី នុត ធ្វើធម៌នៅទីនោះ ។

ដឹងដំណឹងច្បាស់ថា ព្រះអាចារ្យ គង់នៅទីនោះ ក៏ចាត់ឱ្យខ្ញុំចៅអធិការស្តីទី ហួរ ហួន , ឧបាសក អ៊ុំ ឆាំវ ធ្វើដំណើរទៅដល់ភ្នំពេញ ចូលទៅយកភិក្ខុ ចាប ជុំស នៅរៀនឧត្តមវិជ្ជាសាកលវិទ្យាល័យភ្នំពេញ ដែលស្នាក់នៅវត្តកោះ ភ្នំពេញ មួយអង្គ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតធ្វើដំណើរតាមរថភ្លើងពីភ្នំពេញ ទៅបាត់ដំបង ពីបាត់ដំបង ទៅវរណេក្តិកហែប ទើបដល់កន្លែងព្រះអាចារ្យគង់នៅទីនោះសុទ្ធ តែព្រៃស្ងាត់ឈឺងឮតែសូរសត្វយំឆ្លើយឆ្លងគ្នារងំ ភិក្ខុ-សាមណេរ គង់នៅជាមួយព្រះអាចារ្យ ដែលខ្ញុំទៅដល់ឃើញ ចំនួន ១០ អង្គ សុទ្ធតែប្រតិបត្តិធម៌វិបស្សនាធុរៈ អ្នកឧបត្ថម្ភ ឧបាសក ឆឿន ឧបាសិកា លី ពេលថ្ងៃរសៀលអ្នកទាំងពីរនាក់ គាបទឹកអំពៅ ធ្វើភេសជ្ជៈប្រគេនព្រះសង្ឃឆាន់រាល់ថ្ងៃ ដែលពុទ្ធបរិស័ទយក អំពៅមកពីគ្រប់ទិសទី តាមសេចក្តីជ្រះថ្លារបស់ខ្លួន ។

និយាយពីខ្ញុំកូណាអាត្មាវិញ ទៅដល់ថ្វាយបង្គំព្រះអាចារ្យ រួចហើយ ក៏សំពេរះសំណាលសព្វគ្រប់ លោកសួរសុខទុក្ខរួច ហើយ ព្រះអាចារ្យ ស្រី នុត និយាយនឹងខ្ញុំកូណា-អាត្មា ឱ្យរៀន ធម៌វិបស្សនា និយាយហើយនិយាយទៀត ដោយសេចក្តីជ្រះថ្លា របស់ព្រះអង្គខ្លាំងណាស់ ចង់ឱ្យខ្ញុំកូណា-អាត្មារៀនធម៌វិបស្សនា ក្នុងពេលនោះ ខ្ញុំក៏មិនហ៊ានសម្រេចចិត្ត ចាំសួរយោបល់ឧបាសក អ៊ុំ ឆាំង ភិក្ខុ ចាប ដុស លមើលដែលបានទៅជាមួយគ្នា ចំណែកភិក្ខុ ចាប ដុស វិញថា រឿងនេះស្រេចតែលោកបងទេ

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំកូណាមិនហ៊ានថាទេ ចំណែកឧបាសក អ៊ឹ ឆ៉ាទ ថា លោកគ្រូនៅរៀនធម៌មិនកើតទេ ពីព្រោះនៅឯវត្តឯណោះ បើគ្មានលោកគ្រូចាត់ការមិនកើតទេ ខ្ញុំកូណា-អាត្មាឆ្លើយតបវិញ យើងមកនិមន្តលោកឥឡូវ លោកឱ្យអាត្មារៀនធម៌ ហេតុនេះត្រូវតែនៅរៀនតាមសេចក្តីសុំរបស់លោក ប្រហែលជាព្រះអង្គអនុគ្រោះនិមន្តទៅតាមសេចក្តីសុំនិមន្តរបស់យើងហើយ ហេតុនេះខ្ញុំកូណាអាត្មានៅហើយ សូមឱ្យលោកប្អូន ចាប ជុំស ឧបាសក អ៊ឹ ឆ៉ាទ អញ្ជើញ និងនិមន្តមកស្រុកវិញចុះ ។ ព្រឹកឡើងភិក្ខុ ចាប ជុំស ឧបាសក អ៊ឹ ឆ៉ាទ ធ្វើដំណើរត្រឡប់មកវិញ ចំណែកខ្ញុំក៏ចាប់លើកធម៌នឹងព្រះអាចារ្យ លោកមានពុទ្ធដីការថាលើកធម៌ហើយ ខ្ញុំកូណាឆ្លើយថា កូណា សូមជំរាបថា ខ្ញុំកូណា-អាត្មាធ្វើធម៌ក្នុងពេលនោះសឹងយប់បានតែបីយប់ទេ គឺថ្ងៃ ១កើត. ខែ ចេត្រ គ.ស ១៩៦១ ថ្ងៃទី ៤ យកយប់ធ្វើថ្ងៃវិញ គឺមិនសឹងពេលយប់ សឹងតែពេលថ្ងៃ ដើរចង្ក្រមម្តង អង្គុយម្តង រួចពីអង្គុយទៅប្រែធម៌ម្តងដែលខ្ញុំធ្វើក្នុងសំណាក់ព្រះអាចារ្យ លុះដល់ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥កើត ខែចេត្រ ព្រះអាចារ្យប្រាប់ខ្ញុំថា កុំឱ្យសឹងទាំងយប់ទាំង

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃ ។ ខ្ញុំក៏ធ្វើតាមលោក ប៉ុន្តែខ្ញុំកូណា-អាត្មាសូមជំរាបថា មិនសឹងទាំងយប់ទាំងថ្ងៃមហាសែនធ្ងន់ធ្ងរជាទីបំផុត តែខ្ញុំអាចធ្វើបានព្រះអាចារ្យឱ្យធ្វើគ្រប់បីយប់បីថ្ងៃ គិតទៅខ្ញុំធ្វើធមីនៅអណ្ដើកហែប ១៥ ថ្ងៃគត់ ។ លុះដល់ថ្ងៃ ១រោច ខែចេត្រ គ.ស ១៩៦១ លោកគ្រូមហាមោក្ខ យ៉ន នៅអាស្រមស្នាពិមុខ ឃុំខ្ពប ស្រុកសង្កែ ខេត្តបាត់ដំបង ម៉ោង ៩ ព្រឹកបានយកឡានមួយមកនិមន្តព្រះអាចារ្យពីអណ្ដើកហែប មកបង្រៀនធមីនៅអាស្រម្មណ៍ និគមស្រុកបាត់ដំបង ខេត្តបាត់ដំបង ប្រធានអាស្រម្មណ៍ គឺ លោកគ្រូមហា ម៉ុត ។ សូមជំរាបថា ធ្វើធមីនៅអាស្រម្មណ៍និគម យាយ-តា មានចំនួន ៣៥០ នាក់ក្នុងពេលនោះ ។ ខ្ញុំនៅទីនោះបានចំនួន ៣ - ៤ ថ្ងៃ ស្រាប់តែប្អូនជីដូនមួយ អ៊ុំ អ៊ិន ទៅតាមថា ជីតាឡឹត សៅ មានជំងឺធ្ងន់ណាស់ហើយ ចាំតែលោកបងទេ ហេតុនោះបងប្អូនទាំងអស់គេឱ្យខ្ញុំកូណាមកតាមលោកបងទៅកុំខាន ។ ខ្ញុំមកដល់ថ្ងៃហ្នឹងគាត់ក៏អនិច្ចធម្មថ្ងៃហ្នឹងតែម្ដង ធ្វើបុណ្យសពលោកតា ឡឹត សៅ ពីរយប់បីថ្ងៃហើយស្រេចជាស្ថាពរ ។

ចំណែកគណកម្មការវត្តចំបក់បិទមាសវិញ ចាំមើលផ្លូវខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org

កូណា-អាត្មា ទៅរើកយួរម្ជែះ ខ្ញុំក៏ប្រាប់ថា យើងនៅនិមន្តព្រះអាចារ្យឱ្យព្រះអង្គមកគង់នៅវត្តចំបក់បិទមាស ដើម្បីបង្រៀនធម៌វិបស្សនា លុះខ្ញុំកូណា-អាត្មាទៅដល់ ព្រះអាចារ្យនិយាយឱ្យរៀនធម៌ ហេតុនេះបានជាអាត្មានៅរៀនធម៌ ពុទ្ធបរិស័ទសួរខ្ញុំកូណា-អាត្មាគ្រប់គ្នា តើព្រះអាចារ្យនិមន្តមកទេ ? ខ្ញុំកូណា-អាត្មាឆ្លើយថា លោកនិមន្តមកនៅថ្ងៃ ១កើត ខែពិសាខ គ.ស ១៩៦១ នេះ ហេតុនេះយើងខំធ្វើកូបឱ្យលោក ដែលនិមន្តមកជាមួយព្រះអាចារ្យ ព្រមទាំងយាយ-តា ដែលមកគ្រប់ទិសទី សូមជំរាបថា ព្រះអាចារ្យបង្រៀនធម៌បីខែគត់ទើបឈប់សំរាក ព្រះអាចារ្យនិមន្តទៅគង់ចាំវស្សាឯវត្តកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្ដាល ដែលមានចៅអធិការឈ្មោះ **ទូច ទឹម** ត្រូវជាកូនសិស្សរបស់លោក ។

ចាប់តាំងពីព្រះអាចារ្យ មកបង្រៀនធម៌វិបស្សនា វត្តចំបក់បិទមាសមានរស្មីភ្លឺចិញ្ចាចរស់ឡើងវិញ ពុទ្ធបរិស័ទមកធ្វើបុណ្យគ្រប់ទិសទី ភិក្ខុ-សាមណេរ មករៀនសូត្រគ្រប់ទិសទី ហេតុនេះ វត្តចំបក់បិទមាសរុងរឿងក្រៃលែងឡើងវិញ នៅក្នុងគ.ស ១៩៦១

www.budinst.gov.kh www.elibraryofcambodia.org

ដដែលនេះ ខ្ញុំកូណា-អាត្មាជាចៅអធិការស្តីទី ហួរ ហួន បានលាភិក្ខុ-សាមណេរក្នុងវត្តទាំងអស់ ដែលមានលោកគ្រូ សៅ អ៊ែល, ភិក្ខុ ស្រី ឆែម ជាដើម នៅថ្ងៃទី១៥កើត ខែពិសាខ គ.ស ១៩៦១ ដើម្បីទៅនៅខេត្តបាត់ដំបង ឃុំខ្ពប ស្រុកសង្កែ អាស្រមម្នាក់ ស្នាពីមុខ ធ្វើធម៌វិបស្សនាធុរៈ ក្នុងសំណាក់ព្រះអាចារ្យ ស្រី នុត ដែលជាគ្រូរបស់ខ្ញុំ ។

និយាយពីវត្តចំបក់បិទមាសវិញ អត់ពីចៅអធិការស្តីទី ហួរ ហួន ទៅ ភិក្ខុ សៅ អ៊ែល ឡើងជាចៅអធិការជំនួសវិញ ចំណែកសាលាបាលីនៅតែបើកទ្វារដដែល គឺលោកអាចារ្យ ខេម អ៊ែន និមន្តមកពីខេត្តព្រៃវែង អត់ពីអាចារ្យ ខេម អ៊ែន ទៅ មានអាចារ្យថ្មីមកបង្រៀន រហូតដល់ គ.ស ១៩៧០ ។ នៅ គ.ស ១៩៦១ ភិក្ខុ សៅ អ៊ែល ជាចៅអធិការទី ៥ វត្តចំបក់បិទមាស បានដឹកនាំកសាងសាលា ពុទ្ធិកបឋមសិក្សាមួយខ្នង ដែលមានលោក អ៊ុក ទុំ ជួយឧបត្ថម្ភ សាលារៀនមួយខ្នងមានពីរបន្ទប់ របងវត្តពីខាងត្បូង - ខាងលិច ។ ដល់ឆ្នាំ ១៩៧០ ចៅអធិការ សៅ អ៊ែល ក៏លាចាកសិក្ខាបទទៅ គ.ស ១៩៧០ លង្វែកគ្មាន

www.budinst.gov.kh www.elibraryofcambodia.org

ចៅអធិការគ្រប់គ្រងវត្តទេ ហើយប្រទេសកម្ពុជាយើងកំពុងកើតសង្គ្រាមពេញបន្ទុក ព្រោះឯកឧត្តម **លន់ ណុល** បានធ្វើរដ្ឋប្រហារទំលាក់ សម្តេចព្រះនរោត្តម សីហនុ ដែលជាព្រះប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ។ នៅក្នុងវត្តចំបក់បិទមាស ឯកឧត្តម **លន់ ណុល** យកទាហានមកដាក់ក្នុងវត្ត ភិក្ខុ-សាមណេរ នៅជាមួយនឹងទាហាន ពួកទាហានច្បាំងគ្នាទៅវិញទៅមក ជំនាន់នោះគេហៅថា ខាងលើ ឯកឧត្តម **លន់ ណុល** ខាងក្រោម យៀក កុង ច្បាំងគ្នារស់រយៈពេល ៥ ឆ្នាំទើបចប់ ។ គ.ស ១៩៧៥ ខែមេសា គឺថ្ងៃចូលឆ្នាំខ្មែរ ពួកខ្មែរក្រហមយកជ័យជំនះពី **លន់ ណុល** បានរីឯឯកឧត្តម **លន់ ណុល** ក៏រត់ចោលស្រុករហូតទល់ឥឡូវ ។

ហេតុនេះខ្មែរក្រហម **ប៉ុល ពត** , **សុន សេន** , **នួន ជា** **តា ម៉ុក** , **ខៀវ សំផន** , **អៀង សារី** ឡើងកាន់អំណាច ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ពួកគេផ្សឹកព្រះសង្ឃខ្មែរគ្មានសល់ទេនៅក្នុងប្រទេសកម្ពុជាទាំងមូល នេះគឺជារបបដ៏ជូរចត់បំផុត ។

ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ រណសិរ្សសង្គ្រោះជាតិកម្ពុជាដឹកនាំដោយ សម្តេច **ហេង សំរិន** បានវាយរំលំរបបខ្មែរក្រហម

www.budinst.gov.kh www.elibraryofcambodia.org

កាន់កាប់រំលាយរំលំរត់ខ្ចាត់ខ្ចាយ បង្កើតឱ្យមានពុទ្ធសាសនា វប្បធម៌ និងរឿង ដែលជាតិមានពីមុនទាំងប៉ុន្មាន ឱ្យកើតមានឡើងវិញ ប៉ុន្តែក្នុងជំនាន់នោះ មានសារាចរលេខ ០១ ឱ្យបួសពីអាយុ ៥០ ឆ្នាំ ឡើងទៅ ក្មេងមិនឱ្យបួសទេ ។ លុះដល់ គ.ស ១៩៨០ ទើបមាន ព្រះសង្ឃឡើងវិញ ខ្ញុំកូណា-អាត្មា បានអញ្ជើញចាស់ទុំជើងវត្ត ទាំងប៉ុន្មានមកជំនុំគ្នា ដើម្បីរកព្រះសង្ឃមកគង់នៅវត្តចំបក់បិទមាស ពុទ្ធបរិស័ទទាំងអស់ក៏ឆ្លើយស្របគ្នាថា ស្រេចតែលោកគ្រូ គឺខ្ញុំកូណា-អាត្មា **ហួរ ហួន** នេះឯង កាលណោះខ្ញុំកូណា-អាត្មា មិនទាន់បួសទេ ហើយក៏នាំគ្នាសុំច្បាប់បើកវត្តសារជាថ្មីឡើងវិញ ពេលនោះឧបាសក **សុខ ឈុត** ជាអ្នករត់ការរឿងនេះឱ្យបានសម្រេច ។ គ.ស ១៩៨០ ក៏ចាត់គ្នាទៅនិមន្តលោក ដែលមាន **លឹម សុន , សុខ ឈុត , ហួរ ហួន , ឈួន នុយ** នាំគ្នាទៅថ្វាយបង្គំសម្តេចសង្ឃនាយកគណមហានិកាយ **និល ម្នី** គង់នៅវត្តសន្សំកុសល ដើម្បីសុំនិមន្តព្រះតេជគុណ **អ៊ី នូ** មកគង់នៅវត្តរបស់យើង ប៉ុន្តែសម្តេចសង្ឃនាយក **និល ម្នី** មានថេរដីការថា ព្រះតេជគុណ **អ៊ី នូ**

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

បានចាត់ឱ្យទៅគង់នៅវត្ត និរោធរង្សីហើយ នៅតែពីរឬបីថ្ងៃទៀត គណកម្មការវត្តគេមកយកលោកហើយ ហេតុនេះមិនបានទេ ប៉ុន្តែពួកយើងទូលលោក ថាទោះបីមិនបានក៏ដោយ ក៏សុំជួប លោកមួយភ្លែតដែរ ខណៈនោះសម្តេចសង្ឃនាយកឱ្យគេនិមន្ត ព្រះតេជគុណ អ៊ឹុ ឆ្វ មកជួបពួកយើង ។ នៅពេលដែលលោក និមន្តមក លោកក៏មានពុទ្ធដីការទូល សម្តេចសង្ឃនាយក និល ម៉ុនី ថា : នេះគ្រូរបស់ខ្ញុំកូណា ខ្ញុំកូណាបួសមានបំណងតាម លោកគ្រូ ឥឡូវលោកគ្រូខ្ញុំកូណាមកយក ហើយខ្ញុំកូណាត្រូវតែ ទៅ ដូច្នេះខ្ញុំកូណាមិនទៅវត្តនិរោធរង្សីវិញទេ ពេលនោះសម្តេច សង្ឃនាយក និល ម៉ុនី នៅស្ងៀម ។

ហេតុនេះយើងទៅរកលោកមកគង់នៅ វត្តចំបក់បិទមាស បានសម្រេច កំណត់ថ្ងៃទៅយកលោក អ្នកទៅយកព្រះតេជគុណ អ៊ឹុ ឆ្វ គឺ លឹម ស៊ុន ១ , ហេង ហ៊ាំ ១ , ស៊ុខ ឈ៊ុត ១ ពេលព្រះ តេជគុណ អ៊ឹុ ឆ្វ មកដល់វត្តចំបក់បិទមាស ក៏រកកន្លែង ឱ្យលោកគង់នៅ តែព្រះតេជគុណ អ៊ឹុ ឆ្វ មានពុទ្ធដីការថា អាត្មា មិននៅសាលាបាលីទេ អាត្មានៅចេតិយ៍ គឺ (ប្រាង្គ) វិញ ហើយក៏

www.budinst.gov.kh www.elibraryofcambodia.org

នាំគ្នាមកបោសចេតិយ៍ សូមជំរាបថា នៅក្នុងប្រាង្គសុទ្ធតែលាមកដែលពួកពាលមកជុះដាក់ ព្រោះគេយកកន្លែងនេះធ្វើជាបង្គន់របស់គេ លោកក៏គង់នៅទីនេះរហូត ហើយនាំគ្នាហៅលោកថា លោកតាប្រាង្គ។ ពេលនោះវត្តចំបក់បិទមាសមានព្រះសង្ឃមួយអង្គ គឺព្រះតេជគុណ អ៊ីុ នូ នេះឯង ។

មកដល់ព្រង់នេះខ្ញុំកូណា-អាញា សូមជំរាបថា សំណង់នៅក្នុងវត្តចំបក់បិទមាសទាំងអស់នៅសល់តែ ពុទ្ធិកបឋមសិក្សា ១ , ព្រះវិហារ គ្មានដំបូលគ្មានឃឿន ១ និង ចេតិយ៍បីប៉ុណ្ណោះ គឺ : ចេតិយ៍ជ្រុងឥសាន្តព្រះវិហារដែលយើងហៅថាប្រាង្គ ១, ខាងត្បូងព្រះវិហារពីរ គឺ : ចេតិយ៍ លិខិត គំ ១ , ចេតិយ៍ ជា ប៊ិន ១ ។ សំណង់ដែលពួក ប៉ុល ពត កំទេចចោលនោះមានកុដិធំៗ ប្រាំមួយខ្នង , មេរុមួយខ្នង , សាលាបឋមសិក្សាក្មេងរៀនបីខ្នង មានប្រាំបីបន្ទប់ , ចេតិយ៍ប្រាំបួន , បង្គន់បួនបន្ទប់ , រោងវែងមួយខ្នង , ដើមរំពិលប្រាំពីរដើម និង ដើមកកោះមួយដើម ត្រូវពួកគេកំទេចទាំងអស់ ។ ពួកគេបែរជាដាំដើមប្រេងខ្យល់នៅលើឃឿនព្រះវិហារគួរឱ្យអាណោចអាធម្មពន់ពេក នៅក្នុងឆ្នាំ ១៩៨០

www.budinst.gov.kh www.elibraryofcambodia.org

នេះ មានព្រះសង្ឃពីរអង្គទៀតគឺ ភិក្ខុ **ហួរ ហួន** និង ភិក្ខុ **សុខ ឈុត** រួមទាំងអស់បីអង្គព្រះសង្ឃដែលគង់នៅវត្តចំបក់បិទមាស ក្នុងកំឡុងឆ្នាំ ១៩៨០ ដូចមានរៀបរាប់ខាងលើនេះ ។

នៅឆ្នាំមមែ ឯកស័ក ព.ស ២៥២៣ , គ.ស ១៩៨០ នេះ ព្រះអនុគណ ម៉ែន ស្នួន វត្តពូនភ្នំ ស្រុកបាទី និងរដ្ឋអំណាចស្រុកបាទី បានចាត់តាំងភិក្ខុ **ហួរ ហួន** ឱ្យធ្វើចៅអធិការ ប៉ុន្តែខ្ញុំកូណាអាត្មា ប្រកែកមិនធ្វើ ហើយតាំងឱ្យភិក្ខុ **សុខ ឈុត** ធ្វើចៅអធិការវិញ ក៏ព្រមព្រៀងគ្នាឱ្យលោកធ្វើជាចៅអធិការក្នុងពេលនោះទៅ ប៉ុន្តែចៅអធិការ **សុខ ឈុត** ធ្វើបានតែ ៣ ខែលោកក៏ឈប់ធ្វើ ហើយក៏ទៅនៅវត្តស្អាងភ្នំ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ចៅអធិការវត្តចំបក់បិទមាសក៏ធ្លាក់មកលើ ភិក្ខុ **ហួរ ហួន** ដោយស្វ័យប្រវត្តិនៅក្នុងឆ្នាំ ១៩៨០ ជាចៅអធិការទី ៦ វត្តចំបក់បិទមាស ហើយរដ្ឋអំណាច ភូមិ - ឃុំ - ស្រុក ចាត់តាំងឱ្យធ្វើប្រធានគណកម្មការសាងសង់ សាលាបឋមសិក្សា ចំបក់បិទមាស រួមជាមួយគណកម្មការវត្ត និង ពុទ្ធបរិស័ទ នៅឆ្នាំ ១៩៨០ ដដែល សូមជំរាបថា ពេលនោះអាចារ្យសម្រាប់វត្ត គឺ **ណុប ភួន**

www.budinst.gov.kh www.elibraryofcambodia.org

អាចារ្យរង ណៃន ហ្វះ ប្រធានវត្ត ឃួន នុយ អនុប្រធាន លឹម សុន ។ គ.ស ១៩៨០ ដដែលនេះ អាញ្ញាបានឱ្យគណកម្មការឃុំ ពត់សរ ជួយសុំរដ្ឋអំណាចស្រុកបាទី នូវសហករណ៍ភូមិតាំងឫស្សី ដើម្បីយកមកធ្វើសាលាធម្មសភា ។ ចំណែកគណកម្មការ ស្រុក បាទីវិញ គេឱ្យភូមិ - ឃុំ រុះរើសហករណ៍ដឹកយកទៅឱ្យសាលា ស្រុក ហេតុនេះប្រទាំងប្រទាស់គ្នាយ៉ាងសំបើមណាស់ ចំណែកឃុំ មកប្រាប់អាញ្ញាថា ស្រុកគេឱ្យរុះរើយកទៅស្រុក បើដូច្នេះឃុំត្រូវ សួរយោបល់របស់ប្រជាជនទូទៅ ដែលមានភូមិ ១១ នៅក្នុងឃុំ ពត់សរ ប្រជុំលើកទីមួយនៅសហករណ៍ភូមិក្រាំងពោធិ៍ សួរ ប្រជាជនថា សហករណ៍ភូមិតាំងឫស្សី ស្រុកគេឱ្យដឹកនាំយកទៅ ដល់សាលាស្រុកបាទីឱ្យគេ តើបងប្អូនគិតយ៉ាងម៉េច ? ប្រជាជន ឆ្លើយថាយកទៅដាក់វត្តចំបក់បិទមាសវិញ ។ ដល់ថ្ងៃក្រោយទៀត ប្រជុំលើកទីពីរនៅវត្តចំបក់បិទមាស រដ្ឋអំណាចឃុំសួរប្រជាជន ដូចមុនទៀត ប្រជាជនសម្រេចថា រុះរើសហករណ៍ភូមិតាំងឫស្សី មកធ្វើសាលាធម្មសភា វត្តចំបក់បិទមាសវិញ ក៏ចាត់កម្លាំងទាំង ១១ ភូមិ គឺ ភូមិតាំងឫស្សី ១ , ឃ្លាំងសម្បត្តិ ១ , ខ្វាន់មាស ១ ,

www.budinst.gov.kh www.elibraryofcambodia.org

ចំបក់ ១ , ពត់សរ ១ , ខ្នាកូន ១ , ត្រពាំងត្រាវ ១ , ក្រាំងពោធិ៍១ កណ្តាល ១ , ព្រៃស្វា ១ , ក្រូច ១ សូមជំរាបថារុះរើសហ-ករណ៍ ភូមិតាំងឫស្សីតែមួយថ្ងៃទេហើយស្រេច ចាត់កម្លាំងយកមកវត្តមានខ្លះលី ខ្លះសែង ខ្លះរែក ខ្លះទូល តែបីថ្ងៃប៉ុណ្ណោះក៏ជញ្ជូនអស់ ហើយចាប់ផ្តើមសាងសង់ កាលណោះបានយកលោកអាចារ្យ ឆេស ឆុំ នៅភូមិខ្វាន់មាស ជាមេជាង និងសុំកម្លាំងមួយភូមិ ៣ នាក់ ធ្វើរហូតទាល់តែហើយ សូមបញ្ជាក់ថាគ្មានយកលុយកាក់ អីទេ ជាងដែលធ្វើនោះឱ្យតែបាយហូប ពុទ្ធបរិស័ទដែលជួយធ្វើ នោះមានសេចក្តីជ្រះថ្លាពិតប្រាកដ ធ្វើលុះត្រាហើយជាស្ថាពរនៅ ឆ្នាំ ១៩៨០ ធ្វើសាលាធម្មសភានេះ ចំនួន ១៥ ថ្ងៃទើបហើយ ។ គ.ស ១៩៨០ ដដែល ព្រះតេជគុណចៅអធិការវត្តបុទុមសុរិយា បាននិមន្តខ្ញុំកូណា-អាត្មា ទៅបង្រៀនធម៌វិបស្សនាធុរៈ ជាមួយ នឹងឧបាសក ថោង ឯម នៅថ្ងៃ ១រោច ខែអស្សុជ ដែលមានកូន សិស្សចំនួន ១៣០ នាក់ ។

គ.ស ១៩៨១ បានកសាងតួបពីរ ដែលមានអនុប្រធាន **លឹម ស៊ុន** និង លោកតា **ស៊ុខ ឈុត** ព្រមទាំងពុទ្ធបរិស័ទ បាន

www.budinst.gov.kh www.elibraryofcambodia.org

ដឹកនាំអង្គរមួយរទេះទៅដូរឈើនៅភ្នំពេញ យកទៅធ្វើតួប បាន តួបពីរ នៅរហូតសព្វថ្ងៃនេះ បន្ទាប់មកក៏មានព្រះសង្ឃចាស់ៗ បួសកើនឡើងជាលំដាប់គឺៈ ភិក្ខុ ថោង ស៊ែម, ភិក្ខុ ផែន ណាយ ភិក្ខុ យស់ ចក់ , ភិក្ខុ ប៉ែន យឹម , ភិក្ខុ អ៊ុក អ៊ុន , ភិក្ខុ រួញ ចាន់ , ភិក្ខុ ឃួន មុយ ។

ឧបាសក សុន មុយសេង និងភរិយា ព្រៀង ប៊ូ បាន ជាវព្រះអង្គ ដាក់លើបល្ល័ង្កធំ ក្នុងព្រះវិហារ នៅថ្ងៃ ១០ កើត ខែ មិគ្គសិរ ឆ្នាំ រកា ចត្វាស័ក ព.ស ២៥២៦ ត្រូវនឹងថ្ងៃ សុក្រ ទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ អស់តម្លៃ ៥ ជី ។

វត្តចំបក់បិទមាសនៅឆ្នាំ ១៩៨៥ បានជួសជុលដំបូលព្រះ វិហារ អស់តម្លៃ ៤០ ម៉ឺនរៀល ដែលមានឧបាសក ផេង ឧបាសិកា ម៉ិច នៅផ្សារថ្មី ភ្នំពេញ ជួយឧបត្ថម្ភ ។ ចំណែក ឃឿនព្រះវិហារ ជួលរទេះដឹកដីពីត្រពាំងវត្ត ក្នុងមួយរទេះតម្លៃ ៨ រៀល ចំនួន ៨០០ រទេះ ហើយឃឿនព្រះវិហារនេះ ព្រះតេជគុណ ពៅ អ៊ី ជាមេជាង និងភិក្ខុ ណៃ ហួរ , ភិក្ខុ អ៊ុក អ៊ុន ព្រមទាំង ភិក្ខុ-សាមណេរ ។ លោកតា - លោកយាយ ធ្វើសមាធិធម៌ក្នុងវត្ត

www.budinst.gov.kh www.elibraryofcambodia.org

ក៏ជួយធ្វើដែរ ពីឆ្នាំ ១៩៨៧ លោក សេង ម៉ុនហេង និងភរិយា ម៉ិច សុវណ្ណ នៅផ្សារថ្មី ភ្នំពេញ ធ្វើឃឿនព្រះវិហារនេះព្រមទាំងពុទ្ធបរិស័ទផងដែរ ។

នៅឆ្នាំ ១៩៨៨ បានជួសជុលអតីតៈមេរុ គឺ ដំបូល , បង្អួច , ទ្វារ និងក្រាលឥដ្ឋការ៉ូ (សូមជំរាបថា មេរុនេះជួសជុលស្ទើរតែទាំងអស់ ដោយដាក់ឈ្មោះថ្មីថា " ឞូជនីយដ្ឋាន ") អស់តម្លៃ ៥០ ម៉ឺនរៀល ផ្ដើមជួសជុលដោយលោកយាយ ម៉ូ ម៉ៅ នៅទីក្រុងភ្នំពេញ , ឧបាសិកា គួយ ភាក់ , ឧបាសិកា គួយ ហាង វត្តចំបក់បិទមាស ព្រមទាំងពុទ្ធបរិស័ទ្ធជិតឆ្ងាយ ។ តួបភិក្ខុ ថោង ឯម ហៅលោកតាប្រែធម៌ បានមកពីពុទ្ធបរិស័ទនៅភូមិស្វាយតានី អ្នកដឹកនាំគឺ ឧបាសក មៀម , ឧបាសក ម៉ុន , ឧបាសក ហោ , យាយ សយ , តា អែម ព្រមទាំងកូនសិស្សផងដែរ ។ កុដិឈើមួយទៀតដែលហៅ ថា កុដិធំ គឺ កុដិ ឧបាសិកា ញ៉ឹប កាលគាត់ប្រគេនកុដិនេះ គាត់នៅក្រមុំមិនទាន់មានប្ដីទេ គាត់ប្រគេនបច្ច័យចំនួន មួយម៉ឺនរៀល យកទៅទិញផ្ទះនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដឹកនាំមកដល់វត្ត យកជាង មៀម នៅ

www.budinst.gov.kh www.elibraryofcambodia.org

ស្វាយតានីមកធ្វើ បូកសរុបទាំងរស់កុដិនេះ អស់តម្លៃ ១០ ម៉ឺន រៀល ។ ក្លោងទ្វារ សាងសង់ពី ព.ស ២៥៣៤ គ.ស ១៩៩០ ដោយលោក សេខ ប៊ុនហេខ និងភរិយា ម៉ិច សុវណ្ណា ។ ក្លោងទ្វារជាប់ផ្លូវជាតិ សាងសង់ពី ព.ស ២៥៣៤ គ.ស ១៩៩០ ដោយលោក ឡុខ ទ៉េខ ព្រមទាំងគ្រួសារ , លោក តា ម៉ោខ ស៊ុត លោកយាយ ជិន ឈន់ ព្រមទាំងពុទ្ធបរិស័ទផង ដែរ ។ មហាកុដិសាងពី ព.ស ២៥៣៦ គ.ស ១៩៩២ អស់តម្លៃ ៥៨០០០០០០ រៀល (ហាសិបប្រាំបីលានរៀល) ។ ស្រះទឹកនៅចំកណ្តាលភូមិចំបក់បានស្តារឡើងវិញ នៅព.ស ២៥៣៤ គ.ស ១៩៩០ ។ តួបនៅខាងកើតអាពីតះមេរុ អ្នកដឹកនាំ លោកអាចារ្យ សៅ អ៊ែល និងគណកម្មការ លឹម សុន ព្រមទាំងកូនសិស្សគុណ ធ្វើប្រគេនចៅអធិការ ហួរ ហួន កសាងនៅក្នុងព.ស ២៥៣០ គ.ស ១៩៨៦ ។ ជួសជុលសាលាបាលីចាស់ ដោយភិក្ខុ គង់ សារី , ភិក្ខុ អ៊ុច ធន់ថេត នៅក្នុងព.ស ២៥៣៩ គ.ស ១៩៩៥ អស់តម្លៃ ៣ ៥០០ ០០០ រៀល ក្នុងនោះមានឧបាសិកា គួយ គួត ហៅយាយ អរប្សរា បានឧបត្ថម្ភបច្ច័យចំនួន ៨០០ ០០០ រៀល

www.budinst.gov.kh www.elibraryofcambodia.org

ក្រោលឥដ្ឋពណ៌ ។ ស្តារស្រះទឹកព្រះអាចារ្យ ស្រី នុត នៅក្នុង ព.ស ២៥៣២ គ.ស ១៩៨៩ និងធ្វើជណ្តើរផង ។ ស្តារស្រះមុខព្រះវិហារ នៅឆ្នាំ ១៩៨០ និងធ្វើជណ្តើរផង ។ ធ្វើចេតិយ៍នៅក្នុង ព.ស ២៥៣៥ គ.ស ១៩៩១ អស់តម្លៃ ២៥០ ម៉ឺនរៀលកសាង ដោយឧបាសិកា គួយ គួត , ឧបាសិកា គួយ គាត់ , ឧបាសិកា គួយ ហាវ សម្រាប់បញ្ចុះអដ្ឋិធាតុជាសាធារណៈ ។ ធ្វើចេតិយ៍ ព្រះសព មាស ឈឹម , មាស កែប នៅក្នុងព.ស ២៥៤០ គ.ស ១៩៩៦ អ្នកដឹកនាំធ្វើ ចៅអធិការ ហួរ ហួន ។ តួបថ្មប្រក់ក្បឿង នៅជ្រុងឥសាន្តវត្ត ដែលនាងទាំងប្រាំមួយនាក់កសាង ប្រគេនចៅអធិការ ហួរ ហួន ដែលត្រូវជាគ្រូគឺ : នាងរស់ សេរី និង នាង សៀ ចំនួថា , នាង ញឹក ម៉ុនថា និងនាង ម៉ែន សុភារី , លោក សេង ម៉ុនហេង និងភរិយា ម៉ិច សុវណ្ណា និងពុទ្ធបរិស័ទចូលរួមផងដែរ ព្រមទាំងលោកតាលោកយាយ ធ្វើសមាធិធម៌នៅក្នុងវត្តទាំងមូល អស់តម្លៃ ៧៥០០ ដុល្លារអាមេរិក ធ្វើក្នុងព.ស ២៥៣៨ គ.ស ១៩៩៥ ។

www.budinst.gov.kh www.elibraryofcambodia.org

លោកស្រី ទេស់ សេរី និង លោកស្រី សៀ ច័ន្ទថា ទីប្រឹក្សាសម្តេច ជា ស៊ីម បានកសាងគំនូរក្នុងព្រះវិហារ, លាបថ្នាំជញ្ជាំង ខាងក្នុង ខាងក្រៅ, លាបស៊ុំទ្វារ និងបង្អួច, លាបឃឿនព្រះវិហារ, ជួសជុលជណ្តើរបួនខាងលើ ព្រមទាំងនាគផង រួមជាមួយពុទ្ធបរិស័ទជិតឆ្ងាយ ព.ស ២៥៣៩ គ.ស ១៩៩៥ អស់តម្លៃ ១៧ ៨៥០ ដុល្លា ។

ចៅអធិការ ហួរ ហួន បានបង្កើតសមាធិធម៌នៅក្នុង វត្តចំបក់បិទមាស ក្នុងឆ្នាំ ១៩៨១ យាយដែលធ្វើសមាធិមុនគេគឺ ឧបាសិកា សៅ ស៊ីន នៅភូមិចំបក់ ។ ចៅអធិការ ហួរ ហួន បានពង្រីកដីវត្តខិតទៅខាងជើងបានបណ្តោយប្រវែង ១៥០ ម៉ែត្រ និងទទឹងប្រវែង ២៣,៥០ ម៉ែត្រ អ្នកមានសទ្ធាជ្រះថ្លាទិញដីដាក់វត្តគឺ ឧបាសក ឆេង , ឧបាសិកា ម៉ិច នៅផ្សារថ្មី ភ្នំពេញ ឧបាសិកា ហេង ឡុយ ហៅម៉ែអាមុំ នៅកំពុងសោម (ក្រុងព្រះសីហនុ) ឧកញ៉ា ស៊ន សុខណា , ឧបាសិកា មុំ ថាវី ។ ដឹកនាំធ្វើសាលារៀន នៅឆ្នាំ ១៩៨៣ បាន ជួសជុលសាលាចាស់ ៦ បន្ទប់ , ធ្វើថ្មី នៅឆ្នាំ ១៩៨៦ មាន ៣ បន្ទប់, ព.ស ២៥៣៥

www.budinst.gov.kh www.elibraryofcambodia.org

គ.ស ១៩៩១ មាន ២ បន្ទប់ , ព.ស ២៥៣២ គ.ស ១៩៨៨ មាន ៤ បន្ទប់ ។

បណ្ណាល័យមួយខ្នងកសាងដោយ លោកគ្រូ **ម៉ាន់ យ៉ាន** និងភរិយា **កែវ សុខហៃ** នៅឆ្នាំ ១៩៩៦ អស់តម្លៃ ៦៥០០ ដុល្លារអាមេរិក ។ របងបណ្ណាល័យ កសាងដោយ ឧបាសិកា **គួយ ហាវ** និងចៅអធិការ **ហួរ ហួន** អស់តម្លៃ ២២០០ ដុល្លារអាមេរិក ។ ធ្វើសាលាធម្មសភា នៅក្នុងគ.ស ១៩៩៥ អស់តម្លៃ ១៣៣ ដំឡឹង ។ បានជួសជុលរបងវត្តដែលសេសសល់ពីពួកខ្មែរក្រហមកំទេចចោលឱ្យល្អឡើងវិញ ។ បាននាំភិក្ខុ-សាមណេរ និងលោកយាយ លោកតា ដែលធ្វើសមាធិធម៌ក្នុងវត្តចំបក់បិទមាស ព្រមទាំង ពុទ្ធបរិស័ទជិតឆ្ងាយ ទិញគ្រួសក្រហមចាក់ក្រាលថ្នល់ ចាប់ពីថ្នល់ជាតិមកដល់វត្ត មានចម្ងាយ ៣០០០ ម៉ែត្រ និងចាក់ក្នុងវត្តទាំងមូលផងដែរ គឺនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩២ អស់តម្លៃ ៨ ដំឡឹង ។ បើកសាលាពុទ្ធិកបឋមសិក្សា ឱ្យព្រះសង្ឃរៀនសូត្រ នៅក្នុងព.ស ២៥៤០ គ.ស ១៩៩៦ ។ បាននាំភិក្ខុ-

www.budinst.gov.kh www.elibraryofcambodia.org

សាមណេរ លោកយាយ លោកតា សមាធិធម៌ក្នុងវត្តចំបក់បិទមាស ដាំដើមឈើមាន : ដើមស្តៅ , រំពិល , សង្កែ , ប្រេងខ្យល់ កះស្បា , បេង , កាន់ទន ជាដើម ធ្វើឱ្យទឹកដីវត្តចំបក់បិទមាសមានសម្រស់ចម្រើនគួរជាទីជ្រះថ្លា ។ សាលាបាលីថ្មីមានបីបន្ទប់ ស្ថាបនាឡើង នៅក្នុងព.ស ២៥៤២ គ.ស ១៩៩៨ អស់តម្លៃ ៥២ ដំឡឹង ។ ជួសជុលផ្លូវលំ ពីថ្នល់ជាតិមកដល់វត្តមានចម្ងាយ ៣០០០ ម៉ែត្រ ជួសជុលឡើង នៅក្នុងព.ស ២៥៤៣ គ.ស ១៩៩៩ អស់តម្លៃ ៣ ១៨០ ០០០ រៀល ។

## ពុទ្ធសាសនំ ចិរំ តិដ្ឋតុ

សូមឱ្យព្រះពុទ្ធសាសនា រុងរឿងអស់កាលជាយូរអង្វែង

www.budinst.gov.kh www.elibraryofcambodia.org

- ឧបាសិកា ងិម គន់ ព្រមទាំងកូនចៅ ១0000 ៛
- ឧបាសិកា គួយ កាក់ ព្រមទាំងក្មួយៗ ១0000 ៛
- ឧបាសិកា គួយ គួត ព្រមទាំងកូនចៅ ១0000 ៛
- ឧបាសិកា ហេង រួយ ព្រមទាំងកូនចៅ ១0000 ៛
- ឧបាសិកា ងន ពៅ ព្រមទាំងញាតិ ១0000 ៛
- ឧបាសិកា សន រ៉ូច ព្រមទាំងញាតិ ១0000 ៛
- គណាកម្មការ លឹម សុន និងភរិយា ឃុត ស្រីព្រមទាំងបុត្រ ១0000៛
- ឧបាសក សោម ឃឹម ព្រមទាំងកូនចៅ ១0000 ៛
- ឧបាសក ស៊ុក ឧបាសិកា លន់ ព្រមទាំងបុត្រ ១0000 ៛
- ឧបាសិកា រោក ឆេង ១0000 ៛
- ឧបាសក ឃុន ស្រស់ និងភរិយា កែវ ម៉ាច ព្រមទាំងបុត្រ ១0000 ៛
- ឧបាសក ហួរ ឈិន និងភរិយាព្រមទាំងបុត្រ ៦000 ៛
- ឧបាសិកា ងន ហួយ ៥000 ៛
- ឧបាសិកា សៀង នី ៥000 ៛
- ឧបាសិកា ស្រេង ថោ ព្រមទាំងកូនចៅ ៥000 ៛
- ឧបាសិកា សោន់ យ៉ង់ ៥000 ៛
- ឧបាសិកា ទូ លន់ ៥000 ៛
- ឧបាសិកា ប៊ី មឿន ៥000 ៛
- ឧបាសិកា ខឹម សារិ ៥000 ៛

www.budinst.gov.kh www.elibraryofcambodia.org

## នាមសប្បុរសជន អ្នកជួយឧបត្ថម្ភជាប្រាក់ សម្រាប់បោះពុម្ព សៀវភៅប្រវត្តិ វត្តចំបក់បិនមាស

| | |
|---|---|
| - ភិក្ខុ រ៉ុក រ៉ុន | ១0000 ៛ |
| - ភិក្ខុ សុខ ឈុន | ៥000 ៛ |
| - ភិក្ខុ គង់ សារី | ៥ $ |
| - ភិក្ខុ វ៉ាន់ ធី | ១0000 ៛ |
| - ភិក្ខុ សែម គង្គា | ១0000 ៛ |
| - ភិក្ខុ សុត សុខលី | ១0000 ៛ |
| - ឧបាសក ហួរ ហុកសេង ឧបាសិកា សៅ លឿង | ១00000 ៛ |
| - លោក ទន់ យន់ និងភរិយា ហេង មូ ព្រមទាំងកូនចៅ | ២0 $ |
| - ឧបាសិកា មុយ ទន់គួ ព្រមទាំងកូនចៅ | ២0 $ |
| - លោកស្រី សឿ ច័ន្ទថា និងលោកស្រី រស់ សេរី | ៤0000 ៛ |
| - លោកស្រី ញ៉ឹក ប៊ុនថា និងលោកស្រី ម៉ែន សុភារី | ១0 $ |
| - លោកសេង ប៊ុនហេង និងភរិយា ប៊ិច សុវណ្ណ ព្រមទាំងបុត្រ | ១0 $ |
| - ឧបាសិកា ប៉ូ ម៉ៅ ព្រមទាំងកូនចៅ | ១0 $ |
| - ឧបាសិកា គួយ ហាវ ព្រមទាំងញាតិ | ៣0000 ៛ |
| - ឧបាសិកា រ៉ុត យ៉េន ព្រមទាំងកូនចៅ | ២0000 ៛ |

www.budinst.gov.kh www.elibraryofcambodia.org

- ឧបាសិកា ម៉ម ហៀង ៥១០០ ៛
- ឧបាសិកា ទុំ សាស់ ៥០០០ ៛
- ឧបាសិកា ធីត ធីរែម ៥០០០ ៛
- ឧបាសិកា ឡាយ យន់ ៥០០០ ៛
- ឧបាសក ទួន ផូ ៥០០០ ៛
- លោកយាយ លោកតាព្រមទាំងពុទ្ធបរិស័ទទូទៅចំនួន ២៤៣០០ ៛
- លោកយាយ កា ឡុង - វត្តចំបក់បិទមាស ១០០០០០ ៛
- ឧបាសិកា ស៊ូ ផានី ហៅ ញ៉ឹប ព្រមទាំងបុត្រ ១០ $
- លោក ភួច បញ្ញា និងភរិយា ព្រមទាំងបុត្រ ២០០០០ ៛
- ព្រះតេជគុណ ស៊ត ហ៊ត ១០០០០ ៛
- ឧបាសិកា យិន ខែម ឧបាសិកា យិន សួន និងក្មួយ ៨៥០០ ៛
- ឧបាសិកា ជឹម ណែត ៨០០០ ៛
- ឧបាសិកា ម៉ៅ វ៉េត ព្រមទាំងបុត្រ ៥០០០ ៛
- ឧបាសក ចាវ បិន ឧបាសិកា ជុំ សឹម ព្រមទាំងបុត្រ ៥០០០ ៛
- ឧបាសក ចាន់ ធឿន និងភរិយា សេង សុខុម ព្រមទាំងបុត្រ ៥០០០ ៛

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org